**WWF-Cambodia**

21, Street 322,
Boeung Keng Kang I,
Phnom Penh, Cambodia

P.O. Box: 2467
Tel: +855 23 218 034
Fax: +855 23 211 909

www.cambodia.panda.org

WWF *for a living planet*®

| Press Release | For immediate release |
|---|---|

# សត្វក្ដាន់ដែលជាសត្វស្ថិតក្នុងក្រុមប្រភេទជិតផុតពូជ ត្រូវថតបានដោយកាមេរ៉ា ស្វ័យប្រវត្តិលើកដំបូងក្នុងរយៈពេលមួយទសវត្សរ៍នៅភាគខាងកើតនៃប្រទេសកម្ពុជា

**ភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧** – នេះគឺជាលើកដំបូងក្នុងរយៈ១០ឆ្នាំដែលសត្វក្ដាន់ត្រូវថតបានដោយកាមេរ៉ាស្វ័យប្រវត្តិរបស់អង្គការ WWF-**កម្ពុជា** ដែលស្ថិតនៅក្នុងខេត្តក្រចេះ។ សម្រាប់ដំណឹងដ៏រីករាយនេះ យើងពិតជាសង្ឃឹមយ៉ាងមុតមាំថាទៅថ្ងៃអនាគតចំនួនរបស់សត្វក្ដាន់នឹងកើនឡើងនៅក្នុងតំបន់ទេសភាពព្រៃលិចទឹកមេគង្គ។

សត្វក្ដាន់ជំទង់ចំនួន ៤ ក្បាលដោយមានញីពាក្បាល និងឈ្មោល១ក្បាល ត្រូវបានថតបាននៅពេលល្ងាច និងព្រឹកព្រលឹមនៅខេត្តក្រចេះដោយកាមេរ៉ាស្វ័យប្រវត្តិដែលបានដាក់ក្នុងវាលស្រែនៅតំបន់ការពារស្នូលនៃតំបន់ដែលត្រូវបានស្នើដាក់ជាតំបន់ការពារដែល ដែលមានផ្ទៃដីចំនួន **2.678** ហិកតា។ សត្វក្ដាន់ គឺជាប្រភេទសត្វរាត្រីចរត្រូវបានគេប្រទះឃើញកំពុងស៊ីស្រូវពង្រួសទើបលាស់ខ្ចីថ្មីៗនៅក្នុងស្រែ តាមរយៈរូបថតដែលយើងយកមកពិនិត្យ។ ជាមួយគ្នានេះផងដែរ បុគ្គលិករបស់អង្គការ WWF-**កម្ពុជា** ផ្នែកស្រាវជ្រាវ ក៏បានរកឃើញស្នាមដានជើងរបស់សត្វក្ដាន់នៅជុំវិញកន្លែងដែលក្រុមការងារបានដាក់កាមេរ៉ាស្វ័យប្រវត្តិនោះផងដែរ។

សត្វក្ដាន់ គឺស្ថិតនៅក្នុងក្រុមប្រភេទជិតផុតពូជ និងត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ **IUCN** ជាប្រភេទសត្វដែលជិតផុតពូជនៅទូទាំងពិភពលោក ហើយក៏ធ្លាប់បានគេគិតថា វាបានផុតពូជពីប្រទេសកម្ពុជាទៅហើយ រហូតដល់ឆ្នាំ ២០០៦ នៅពេលដែលវាត្រូវបានគេរកឃើញឡើងវិញនៅក្នុងខេត្តក្រចេះ ហើយចាប់តាំងពេលនោះមក វាមិនត្រូវបានគេប្រទះឃើញនៅក្នុងព្រៃជាថ្មី តាមរយៈម៉ាស៊ីនថតរូបស្វ័យប្រវត្តិណាមួយឡើយ ។

ការគំរាមកំហែងចំបងៗ ចំពោះសត្វក្ដាន់ រួមមានការប្រម៉ាញ់ ការដាក់អន្ទាក់ ការបាត់បង់ទីជម្រក សកម្មភាពរបស់មនុស្សក្នុងការឈូសឆាយដីព្រៃ និងទន្ទ្រានដីព្រៃដើម្បីធ្វើចំការ សាងសង់លំនៅដ្ឋានជាដើម។

លោក ផានចាន់ណា មន្ត្រីផ្នែកស្រាវជ្រាវនៅអង្គការ WWF - **កម្ពុជា** និងនិស្សិតសាកលវិទ្យាល័យផ្នែកជីវវិទ្យា គុត ស្រីមួយ និងសមាជិកក្រុមល្បាតសត្វក្ដាន់ គឺជាអ្នកដែលបានរៀបចំដាក់កាមេរ៉ាស្វ័យប្រវត្តិនៅកន្លែងដែលសត្វក្ដាន់បានបង្ហាញខ្លួន ដោយប្រជាជនសហគមន៍នៅទីនោះបានរាយការណ៍មកក្រុមការងាររយើង។

លោក ផាន ចាន់ណា បានបញ្ជាក់ទៀតថា ម្ចាស់ស្រែដែលបានរាយការណ៍ពីការប្រទះឃើញសត្វក្ដាន់ គឺពីដើមឡើយជាអ្នកដែលមិនគាំទ្រការការពារសត្វក្ដាន់ឡើយ ប៉ុន្ដែពេលនេះពួកគាត់បានក្លាយជាសមាជិកសហគមន៍ដែលចូលរួមក្នុងការការពារកាមេរ៉ាស្វ័យប្រវត្តិ និងចូលរួមបង្កើតក្រុមល្បាតសហគមន៍ដើម្បីការពារសត្វក្ដាន់ផងដែរ។ ជាមួយគ្នានេះដែរ ម្ចាស់ស្រែទាំងនោះពេលនេះបានយល់ដឹងថាយ៉ាងច្បាស់ថាសត្វក្ដាន់ គឺមិនបានបំផ្លិចបំផ្លាញដំណាំស្រូវរបស់ពួកគេឡើយ តែផ្ទុយទៅវិញ សត្វក្ដាន់មានប្រយោជន៍ខ្លាំងណាស់សម្រាប់ប្រព័ន្ធអេកូឡូស៊ី ហើយពួកវាក៏អាចបង្កើតឱកាសសម្រាប់វិស័យអេកូទេសចរណ៍ផងដែរ។ ជាក់ស្ដែងណាស់ តាមរយៈរូបភាពសត្វក្ដាន់និងស្នាមដានជើងរបស់ពួកវាដែលទទួលបាននាពេលនេះ គឺបានបង្ហាញយ៉ាងប្រាកដថាចំនួនរបស់ពួកវាកើតមានឡើងវិញហើយ។

លោកសេង ទៀក នាយកអង្គការ WWF ប្រចាំប្រទេសកម្ពុជាបានមានប្រសាសន៍ថា "អ្វីដែលយើងបានឃើញនាពេលនេះ គឺជាការឆ្លុះបញ្ចាំងដោយផ្ទាល់ពីការខិតខំប្រឹងប្រែងរបស់សមាជិកសហគមន៍ និងបុគ្គលិកទាំងអស់ ពិសេសនោះការចូលរួមគាំទ្រយ៉ាងសកម្មពីរដ្ឋាភិបាលកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ លទ្ធផលទាំងអស់នេះ គឺជាការលើកទឹកចិត្ត និងជាដំណឹងដ៏រំភើបរីករាយបំផុតសម្រាប់យើងទាំងអស់គ្នា។ ទោះជាយ៉ាងណាក៏ដោយ មានបញ្ហាជាច្រើនដែលយើងត្រូវតែបន្តដោះស្រាយជាបន្ទាន់ពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមនានាដូចជាការបរបាញ់ ហើយដែលតម្រូវឲ្យយើងត្រូវតែបន្តការកិច្ចប្រឹងប្រែងបន្ថែមទៀត និងការយកចិត្តទុកបំផុត ជាពិសេសនោះ គឺការពង្រឹងការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព។"

គម្រោងអភិរក្សសត្វក្ដាន់ គឺជាគម្រោថ្មីដែលត្រូវបានបង្កើតឡើងដោយអង្គការ WWF នៅឆ្នាំ ២០១៤ នៅក្នុងតំបន់ទេសភាពព្រៃលិចទឹកមេគង្គ។ សម្រាប់ការងារបន្ទាប់ គឺជាការផ្ដោតការយកចិត្តទុកដាក់ក្នុងការអង្កេត និងតាមដានវត្តមានរបស់សត្វក្ដាន់តាមរយៈការដាក់កាមេរ៉ាស្វ័យប្រវត្តិ ការពង្រឹងការអនុវត្តច្បាប់ កម្មវិធីអប់រំផ្សព្វផ្សាយ ការល្បាតរបស់សហគមន៍ និងធ្វើផែនការរៀបចំសម្រាប់តំបន់ការពារសត្វក្ដាន់នេះទៅជាដែនជម្រកសត្វព្រៃស្របច្បាប់ គឺត្រូវធានាថាការអភិរក្សសត្វក្ដាន់ គឺជាអាទិភាពដែលត្រូវបានទទួលស្គាល់ទូទាំងប្រទេស។

###

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

សម្រាប់រូបភាពសត្វក្ដាន់ដែលថតបានដោយកាមេរ៉ាស្វ័យប្រវត្តិអាចទាញយកបានតាមរយៈ៖
https://drive.google.com/open?id=0B3-3_0ERIkx4Q1dJYndVaUpDSHc

លោក អ៊ុន ចក្រី ប្រធានផ្នែកទំនាក់ទំនងរបស់អង្គការ WWF-**កម្ពុជា**
ទូរស័ព្ទ : **+855 (0)១៧ ២៣៤ ៥៥៥**
**Email:** Chakrey.un@wwfgreatermekong.org

**អំពីអង្គការ** WWF-**កម្ពុជា**

អង្គការWWF បានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥ដែលជាផ្នែកមួយនៃអង្គការWWF ក្នុងមហាតំបន់ទន្លេមេគង្គ។ បេសកកម្មរបស់អង្គការWWF គឺធានាឲ្យមានការចូលរួមគាំទ្រពីមនុស្សគ្រប់រូបដើម្បីធ្វើការអភិរក្សនូវជីវចម្រុះដ៏សម្បូរបែបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការWWF-កម្ពុជា នឹងជម្រុញឲ្យមានឱកាសថ្មីៗជាច្រើនដែលផ្តល់ផលប្រយោជន៍ដល់មនុស្ស និងធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រតាមរយៈការលើកទឹកចិត្តឲ្យមានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ សម្រាប់ព័ត៌មានលំអិតសូមចូលទៅកាន់គេហទំព័ររបស់អង្គការWWF-**កម្ពុជា** cambodia.panda.org